ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

បេឡាជាតិសន្តិសុខសង្គម

លេខ : ០៧៥/២១ ប.ស.ស.

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារចង្អៀតពិនិត្យសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទនិងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ

## បេឡាជាតិសន្តិសុខសង្គម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)
- យោងតាមការចាំបាច់របស់បេឡាជាតិសន្តិសុខសង្គម

## សម្រេច

**ប្រការ១** .-

ត្រូវបានបង្កើតក្រុមការងារចង្អៀតដើម្បីពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកប្រាក់សោធនសម្រាប់បុគ្គលនៃវិស័យសាធារណៈ មុននឹងដាក់ប្រជុំក្នុងក្រុមថ្នាក់ដឹកនាំ ប.ស.ស.។

ក. សមាសភាពក្រុមការងារនេះមានដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ស៊ុំ សោភ័ណ** | អគ្គនាយករង ប.ស.ស. | ប្រធាន |
| ៣-ឯកឧត្តម **ហេង សុផាន់ណារិទ្ធ** | ប្រធាននាយកដ្ឋានសេវាអតិថិជន និងទំនាក់ទំនងសាធារណ: | សមាជិក |
| ៤-លោក **គាត ពុធណារិទ្ធិ** | ប្រធាននាយកដ្ឋានគ្រប់គ្រងការវិនិយោគ មូលនិធិសន្តិសុខសង្គម | សមាជិក |
| ៥-លោក **សុក បូរ៉ា** | ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម | សមាជិក |
| ៦-លោក **ហុង សុខហៀប** | ប្រធាននាយកដ្ឋានបញ្ជិកានិងភាគទាន | សមាជិក |
| ៧-លោក **លៀង ពន្លក** | ប្រធាននាយកដ្ឋានគោលនយោបាយ សន្តិសុខសង្គម | សមាជិក |
| ៨-លោក **ហុក ម៉ុងហ៊ត** | ប្រធានការិយាល័យប្រាក់សោធន | សមាជិកអចិន្ត្រៃយ៍ |

ខ. **ក្រុមការងារនេះមានតួនាទីនិងភារកិច្ច:** ពិនិត្យកែសម្រួលលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអនុវត្តផ្នែកសោធនសម្រាប់បុគ្គលនៃវិស័យសាធារណ:ឱ្យមានលក្ខណ:គ្រប់ជ្រុងជ្រោយយ៉ាងយូរត្រឹមថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ មុនដាក់ប្រជុំក្នុងក្រុមថ្នាក់ដឹកនាំ ប.ស.ស.។

**ប្រការ២ .-**

សមាជិកក្រុមការងារនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៣ .-**

ការិយាល័យប្រាក់សោធននៃនាយកដ្ឋានតាវកាលិកសន្តិសុខសង្គម ជាសេនាធិការឱ្យក្រុមការងារនេះ ដែលមានភារកិច្ចរៀបចំសំណុំឯកសារសម្រាប់ការប្រជុំ រៀបចំការប្រជុំ ធ្វើកំណត់ហេតុ និងរបាយការណ៍កិច្ចប្រជុំរបស់ក្រុមការងារ។

**ប្រការ៤ .-**

ឯកឧត្តម លោក លោកស្រី ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២១

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**
**អគ្គនាយកបេឡាជាតិសន្តិសុខសង្គម**

**អ៊ុក_សមវិទ្យា**